# របាយការណ៍

## ស្តីអំពីតាំងសម្លាប់និងសន្តិសុខនៅស្រុកកោះធំ និង ស្រុកល្វាឯម ខេត្តកណ្តាល

## ថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០០១

### ១) ស្រុកកោះធំ

ស្រុកកោធំជាស្រុកមួយដែលស្ថិតនៅខាង.........ខេត្តកណ្ដាល និងស្ថិតនៅភូមិភាគនិរតីនៃប្រទេស ។ កាលពីឆ្នាំ១៩៩៥ ក្រុមស្រាវជ្រាវមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើកាស្រាវជ្រាវម្ដងរួចទៅហើយ ប៉ុន្តែនៅមានទីតាំងមួយចំនួនទៀតដែលពុំទាន់បានចុះទៅដល់ដោយមូលហេតុផ្លូវលំបាក ។ ដូច្នេះក្រុមស្រាវជ្រាវបន្តស្រាវជ្រាវនៅទីតាំងទាំងឡាយដែលពុំបានចុះម្ដងទៀតនៅក្នុងស្រុកកោះធំនេះ ។ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាពុំបានចូលជួបលោកអភិបាលស្រុកក៏ដូចជាវប្បធម៌ពត៌មានស្រុកឡើយ នៅខែទឹកដំឡើងធ្វើឲ្យទឹកហូរបុកដីខ្ទាំង បណ្ដាឲ្យផ្លូវដែលនៅចម្ងាយពី សាលាស្រុកប្រហែលជាមួយគីឡូម៉ែត្រត្រូវដាច់ ហើយក្រុមអ្នកជំនាញខាងស្ពានកំពង់តែដំណើរការធ្វើស្ពាន ដូច្នេះក្រុមរបស់យើងពុំបាន ចូលទំនាន់ទំនងខាងសាលាស្រុកឡើយ ។ ម្យ៉ាងពេលវេលាមួយថ្ងៃ ពុំអាចនៅរង់ចាំយូរតទៅទៀតបាន ក៏សំរេចចិត្តចុះទៅជួបលោកប្រធានឃុំតែម្ដង ។

#### ឃុំកណ្ដាលកោះធំ«ក»

**ទីតាំងព្រៃកក្បាលខ្មោច** លេខកូដ ០៨០៤០៤

រយៈកំពស់(N) ១១° ០៩' ២៨: ៨៦" រយៈទទឹង(E) ១០៥° ០៤' ២៦: ៧២"

ព្រៃកក្បាលខ្មោចគឺជាទីតាំងសម្លាប់ដ៏ធំមួយ ដែលប្រជាជនទូទាំងឃុំកោះធំ«ក»ទាំងមូលបានដឹងយ៉ាងច្បាស់អំពីទីតាំងនេះ ។ ទីតាំងព្រៃកក្បាលខ្មោចស្ថិតនៅក្នុងភូមិកណ្ដាលកោះធំ ឃុំកោះធំ«ក» ដែលមានចម្ងាយពីសាលាឃុំកោះធំមួយគីឡូម៉ែត្រកន្លះ ទិសខាងត្បូងឆៀងខាងកើត ។ ដោយសារខែសីហានេះជារដូវវស្សាធ្វើឲ្យមានការលំបាកនៅក្នុងការធ្វើដំណើរទៅរកទីតាំង ដូច្នេះក្រុមរបស់យើងបានបែងចែកជាពីរក្រុម មួយក្រុមបានធ្វើដំណើរតាមទូកឆ្ពោះទៅរកទីតាំង ដោយមានលោកប្រធានឃុំជាអ្នកនាំផ្លូវ មួយក្រុមនៅសម្ភាសន៍ជាមួយសាក្សីចំនួន២នាក់គឺលោកអ៊ំ សាំង ទិត្យ និង លោកអ៊ំ នៅ ផូន នៅផ្ទះប្រធានឃុំ ។ លោកអ៊ំ សាំង ទិត្យ អាយុ៦២ឆ្នាំ ជាប្រជាជនចាស់ដែលបានរស់នៅក្នុងភូមិកណ្ដាលកោះធំ ឃុំកោះធំ«ក» ស្រុកកោះធំនេះ

គ្រប់ជំនាន់ទាំងអស់ ដូច្នេះលោកអ៊ំបានដឹងពត៌មាននេះច្បាស់ ហើយលោកអ៊ំក៏បានផ្តល់នៅបទសម្ភាសន៍ដល់ក្រុមស្រាវជ្រាវរបស់យើងដែរ ។ លោកអ៊ំបានមានប្រសាសន៍ថា នៅក្នុងឆ្នាំ១៩៧៥គាត់មានតួនាទីជាប្រធានកងនេសាទ នៅក្នុងភូមិកណ្តាលកោះធំនេះតែម្តង ដោយសារនៅក្នុងភូមិកណ្តាលកោះធំមានការរីកចំរើនខាងផ្នែកនេសាទ គាត់ក៏បានត្រូវតែងតាំងជាសាទឃុំ រហូតដល់ថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ ។ កន្លែងទីតាំងព្រៃក្បាលខ្មោចគ្មានភូមិដ្ឋានអីទេ កន្លែងហ្នឹងជាដីទួលខ្ពស់ជាងគេ ហើយព្រៃកហ្នឹងគេជីកសំរាប់យកទឹកធ្វើស្រូវប្រាំងក្នុងកោះហ្នឹង ។ ព្រៃកក្បាលខ្មោចគ្មានមន្ទីសន្តិសុខទេ គឺជាទីតាំងសម្លាប់ជនរងគ្រោះតែម្តង ជនរងគោះដែលយកមកសម្លាប់នៅទីនេះ ភាគច្រើនគឺយកចេញពីមន្ទីរ សន្តិសុខនៅពោធិទន្លេពោធិទន្លេគឺជាមន្ទីសន្តិសុខដ៏ធំមួយនៅក្នុងស្រុកកោះធំ ប៉ុន្តែទីតាំងពោធិទន្លេនេះយើង បានទៅតាំងពីឆ្នាំ១៩៩៥មកម្លេះ ។ ពោធិទន្លេះមានចម្ងាយប្រហែល២គីឡូម៉ែត្រពីទីតាំងព្រៃកក្បាលខ្មោច គឺស្ថិតនៅទិសខាងជើងឆៀងខាងកើត ។

លោកអ៊ំ សាំង ទិត្យ មានប្រសាសន៍ថាៈ ខ្ញុំពេលសម្លាប់ណឹង កន្លែងព្រៃកខ្មោចហ្នឹងអត់បានដួបទេ តែបើនៅក្នុងអូរខែប្រាំអី ខ្ញុំរកត្រីហ្នឹង ឃើញវៃនៅមុខខ្ញុំក៏មានដែរ វៃនឹងត្បូងចប វៃនឹងប៉ែលក៏មានដែរ ។ បើនិយាយទៅក្នុងអូរហ្នឹង កន្លែងណាក៏មានកន្លែងកប់ដែរ (កន្លែងកប់ក្នុងអូរគឺនៅក្បែៗទួលព្រៃកកប់ខ្មោច) ។

អគ្គភាពរបស់ខ្ញុំមានមង មានអួន ប្រវែង៥០០ម៉ែត្រ ។ មានមងក៏មាន ខែទឹកអញ្ចឹងដាក់លប ។ នៅអគ្គភាពរបស់លោកអ៊ំមានអួនប្រវែង៥០០ម៉ែត្រ អូសដោយកម្លាំងមនុស្សចំនួនពី២០ទៅ៣៥នាក់ អូសក្នុងមួយថ្ងៃគឺតម្រូវឲ្យអូសត្រីឲ្យបាន៣តោន ។ គាត់បាននិយាយថាត្រីដែលអូសបានគឺយកទៅចែកតាមសហករណ៍ ក៏ប៉ុន្តែធាតុពិតប្រជាជនមិននៅក្នុងសហករណ៍សូវបានហូបទេ មិនដឹងគេយកទៅណា ។ លោកអ៊ំបានប្រាប់ថា នៅក្នុងបរិវេនជុំវិញទីតាំងព្រៃកក្បាលខ្មោចនេះ គឺគ្មានប្រជាជនណាមានសិទ្ធិចូលទេ បើប្រជាជនណាហ៊ានចូលតែមួយជំហានគឺមិនអាចវិលមោផ្ទះវិញបានឡើយ គឺមានតែក្រុមនេសាទតែមួយ គត់ដែលមានសិទ្ធិចូលក្នុងបរិវេននេះបាន ដូច្នេះកាលដែលអ៊ំបានឃើញផ្ទាល់ភ្នែកនេះក៏ដោយសារតែការធ្វើ នេសាទនេះដែរ ។ ឆ្នាំ១៩៧៦-១៩៧៧គឺជាឆ្នាំដែលស្លាប់ខ្លាំងជាងគេនៅទូទាំងស្រុកកោះធំ សម្លាប់ទាំងប្រជាជនចាមទាំងកងទ័ព ប្រជាជនសុទ្ធសាធក៏មាន ។ ប្រជាជនចាមគឺពួកខ្មែរក្រហមដឹកយកមកទាំងទូកពីឃុំបារែន ស្រុកកោះធំយក មកសម្លាប់នៅព្រៃកក្បាលខ្មោចនេះ គឺសម្លាប់នៅពេលល្ងាចជិតយប់តែម្តង ។ លោកអ៊ំបានផ្តល់នូវបទសម្ភាសន៍ជាមួយក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារយើងថាៈ ក្រុមរបស់ខ្ញុំគឺមានផែនការសម្លាប់នៅក្នុងឆ្នាំ១៩៧៨ ព្រោះខ្ញុំនៅអគ្គភាពកងនេសាទណឹងគឺថាបានដឹងផែនការគេខ្លះៗដែរ គោលបំណងប្រុងសម្លាប់ គេឲ្យជីករណ្តៅហើយគេថា «បើពូស្ទូរគ្រាប់ផ្ទុះអីណឹងឲ្យរត់ចូលរណ្តៅទៅដើម្បីការពារខ្លាចគ្រាប់វា

ប៉ះពារ ប៉ុន្តែគោលបំណងគេច្បាស់ជាដាក់គ្រាប់ក្នុងរណ្តៅហ្នឹង បើយើងចូលច្បាស់ជាងាប់ក្នុងរណ្តៅហ្នឹងម៉ង» ប៉ុន្តែជាសំណាងល្អនៅក្នុងពេលនោះគឺមានកងទ័ពរណសិរ្សរំដោះប្រទេសជាតិ បានមករំដោះប្រទេសទាន់ពេលវេលាទើបក្រុមរបស់គាត់បានរស់រានមានជីវិតមកទល់សព្វថ្ងៃ ។ គាត់បានដឹងផែនការសម្លាប់នេះពីឈ្មោះ ស្រឿន ជាប្រធានកងសោទ គាត់បានទទួលញ្ញាបីថ្នាក់លើមោ ប៉ុន្តែសព្វថ្ងៃនេះឈ្មោះស្រឿនស្លាប់បាត់ហើយ ។ នៅក្រោយឆ្នាំរំដោះប្រទេជាតិ ១៩៧៩ លោកអ៊ំបានទៅដល់មន្ទីរសន្តិសុខពោធិទន្លេ ហើយក៏យកបានសៀវភៅរបស់ខ្មែរក្រហមមួយក្បាល ដោយមានសរសេរដាក់ថា កម្លាំងត្រៀម បញ្ជើរអីមានសព្វទាំងអស់ ហើយវាបានដាក់ថាកម្លាំងណាដែលត្រូវកម្ទេចនៅពេលណា កម្លាំងណាត្រូវកម្ទេចនៅពេលណាអីមានរបស់គេទាំងអស់ ហើយនឹងមានគូសក្រឡោនប៊ិចក្រហមដោយខ្លួន គាត់បានសន្និដ្ឋានថាឈ្មោះដែលកូសក្រឡោនប៊ិចក្រហមនេះប្រហែលជាប្រុងយកទៅសម្លាប់ហើយ ហើយក៏បានឃើញមានខ្នោះ និងរនុកសំរាប់ដាក់អ្នកទោសនៅផ្ទុយគ្នាទៀតផង ។ លោកអ៊ំ សាំង ទិត្យ បានទៅឃើញប្រជាជនដែលកំពង់តែជីកគាស់កកាយរណ្តៅសាកសពជនរងគ្រោះនៅទីតាំងព្រៃកក្បាលខ្មោច ដើម្បីរកមាសប្រាក់ ហើយក៏បានប៉ាន់ស្មានចំនួនរណ្តៅសាកសពនោះថា រណ្តៅយ៉ាងតិចក៏ពី៣០ទៅ៤០រណ្តៅ ហើយគាត់បានប៉ាន់ស្មានចំនួនជនរងគ្រោះក្នុងមួយរណ្តៅៗ បើតិចក៏មួយរយនាក់ដែរក្នុងមួយរណ្តៅ ការប៉ាន់ស្មានចំនួនរងគ្រោះសរុបទាំងអស់ពី៣០០០ទៅ៤០០០នាក់ ។ លោកអ៊ំបានញ្ញាក់ប្រាប់ដល់ក្រុមស្រាវជ្រាវយើងថា នៅទីតាំងសម្លាប់ផ្សេងៗពេលរៀបសម្លាប់គឺពួកខ្មែរក្រហមចាក់មេក្រូយ៉ាងទ្រហឹងអឺងកង ដើម្បីជាការបន្លប់កុំឲ្យប្រជាជនក្នុងភូមិឮសូរសម្រែកជនរងគ្រោះស្រែក ប៉ុន្តែចំពោះទីតាំងសម្លាប់ព្រៃកខ្មោចវិញ នៅពេលរៀសម្លាប់មិនបានចាក់មេក្រូដូចកន្លែងផ្សេងៗទេ ព្រោះទីតាំងនេះវានៅដាច់ស្រយាលពីភូមិរបស់អ្នកស្រុក ។

លោកអ៊ំ នៅ ងួន អាយុ៦៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិកណ្តាលកោះធំ ឃុំកោះធំ«ក» ស្រុកកោះធំ ខេត្តកណ្តាល ។ ឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ ក៏រស់រស់នៅភូមិកណ្តាលកោះធំ ឃុំកោះធំដដែល ។ លោកអ៊ំបានមានប្រសាសន៍ថាៈ ខ្ញុំបាទក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យខ្ញុំបាទការងារនោះវាច្រើនផ្នែកណាស់ ផ្នែកខាងភ្ជួរដីនោះផ្សេងទៅ ផ្នែកខាងដងប៉ែលនោះផ្សេងទៅ ផ្នែករែកដីនោះផ្សេងទៅ ឲ្យសែងបេតុងនោះខ្លះទៅ ដូចនេះការងារខ្ញុំមិនចំពោះមុខទេ ។ ហើយរយៈពេលដែលការងារគេហៅថាការដ្ឋានស្រះ៨នេះខ្ញុំបាទរស់នៅខាងកងប៉ែល ។ កងប៉ែលដូចថាយើងលើកទំនប់លើភ្លឺអី ។ ហើយរយៈពេលខ្ញុំនៅស្រះ៨ណឹងខ្ញុំបាទកំនើតកូនខ្ញុំមួយសព្វថ្ងៃនេះ វាគ្រប់ខែជិនាន់នោះ គេហៅថាមេភូមិ ចុះជំនាន់នោះគេមានសិទ្ធិខ្លាំងណាស់ចៅហ្វាយស្រុកឥឡូវមានសិទ្ធិមិនស្មើគេទេ ។ អត់មានឲ្យខ្ញុំមោទេ ដល់មេឃុំមួយឈ្មោះឆេង បានមកប្រាប់ខ្ញុំដល់កន្លែងការដ្ឋាននោះថាឲ្យខ្ញុំមកផ្ទះ ពួងឯងឲ្យខ្ញុំមោផ្ទះម៉េចបើបងវ៉ែនៗ សព្វថ្ងៃគាត់នៅរស់ កាលនោះគាត់

ធ្វើជាមេភូមិគាត់មិនឲ្យខ្ញុំមោទេ ដល់នេះមេឃុំហ្នឹងដេញខ្ញុំឲ្យមោផ្ទះ ហ្អី! ផ្លូនឯងមោផ្ទះដល់ពេលហើយ ដល់មោដល់ផ្ទះភ្លាមរ៉ែនថា ផ្លូនឯងនរណាឲ្យមោផ្ទះ? ខ្ញុំថាឆេងមេឃុំ យីមោផ្ទះកុំនៅទំនេរធ្វើការនាយអាយ ទៅ ។ ខ្ញុំគោរពតាមការបាត់តាំងឲ្យតែបានមោផ្ទះ ។ ទទួលព្រលឹមឡើងគេឲ្យខ្ញុំសែងបេតុងសសរ៤ជ្រុងគេរុះ ។ បេតុងហ្នឹងគេថាយកទៅកសាងលូតាំងពីសំប៉ាន់រហូតដល់ព្រែកជីហាយ ស្នាខ្ញុំសែង ។ វាឲ្យ៤នាក់ស្នែង២ ចង់ប្រវែងណាក៏ដោយ អាជើងទាអញ្ចឹងថាអត់ឲ្យបែកទេ តែបែកមានទោសទៀត ថ្មមណាស់សែងហ្នឹង ។ លោកអ៊ំ នៅ ផ្លូន បានប្រាប់ថា អ្នកដែលធ្វើការទាំងនេះសុទ្ធតែមានទោសកំហុស ដូចគាត់ស្ថិតនៅក្នុងប្រភេទ ត្រៀម វាតាមដាន ព្រោះមានបងគាត់ម្នាក់ធ្វើជាមេភូមិនៅកោះថ្មី ដូច្នេះនៅជំនាន់ខ្មែរក្រហមគេទម្លាក់ទៅ តាមខ្សែ ។ លោកអ៊ំខិតខំធ្វើការទាំងឈឺទាំងជា ធ្វើយ៉ាងម៉េចឲ្យតែបានរស់ ពេលឈឺម្តងៗគេឲ្យទៅដេកពេទ្យ ដោយមានថ្នាំព្យាបាល(ថ្នាំអាចម៍ទន្សាយ) ដែលមានជាតិល្វីងៗហើយរឹងៗបេះតែប្រឹងលេប ជួនកាលក៏ត្រូវ ជួនកាលក៏អត់ ។ លោកអ៊ំ នៅ ផ្លូន ជាប្រជាជនចាស់រស់នៅភូមិ កណ្តាលកោះធំ ឃុំកោះធំ ដូចលោកអ៊ំ សាំង ទិត្យដែរ ហើយក៏បានដឹងពត៌មានដូចគ្នា ដូច្នេះគាត់បានឯកភាពទាំងស្រុងនៅការរាយការណ៍របស់លោក អ៊ំ សាំង ទិត្យ ទាំងប៉ុន្មានខាងលើ អំពីទីតាំងព្រែកក្បាលខ្មោចនេះ ។

**ទីតាំងគុក សន្តិសុខ និង កន្លែងសម្លាប់ក្បាលដំរីក្រោម លេខកូដ ០៨០៨០៥**

ទីតាំងនេះស្ថិតនៅក្នុងភូមិក្បាលដំរីក្រោម ឃុំកំពង់កង់ ស្រុកកោះធំ នៅចំខាងក្រោយផ្ទះលោកតា ហែម ឆឹងតែម្តង ។ លោកតា ហែម ឆឹង អាយុ៧៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្បាលដំរីក្រោម ឃុំកំពង់កង់ ស្រុកកោះធំ ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៣ពួកខ្មែរក្រហមបានយកផ្ទះរបស់គាត់ធ្វើជាមន្ទីរ សន្តិសុខ រួចហើយ ពួកវាបានជម្លៀសលោកអ៊ំឲ្យទៅនៅកៀនស្វាយ លុះដល់ឆ្នាំ១៩៧៨ទើបគាត់ ត្រឡប់មកវិញ មកនៅត្រឹម អង់កូ ហើយគាត់បានមកលួចមើល ពីព្រោះគាត់សង្ស័យថាគេយកមកដាក់ពេញៗអញ្ចឹង វាយកទៅណាអស់ ដល់មកពួកខ្មែរក្រហមបានរុះផ្ទះរបស់គាត់ទៅធ្វើជារោងបាយ នៅភូមិក្បាលដំរីក្រោម មុខវត្តកោះធំ ។ ហើយគាត់ក៏នពត៌មានពីអ្នកស្រុកថា ជនរងគ្រោះដែលជាប់នៅផ្ទះរបស់គាត់ ខ្លះថាយកទៅអញ្ចេះ ខ្លះថាយក ទៅមូលដ្ឋាន ខ្លះគេថាយកទៅប្រលែង(ពាក្យថា ប្រលែងនោះគឺវៃចោលហើយ) ។ ជនរងគ្រោះដែលជាប់នៅ មន្ទីរសន្តិសុខនេះគឺមានអ្នកដែលនៅក្នុងស្រុកនេះក៏មាន អ្នកមកពីឆ្ងាយក៏មាន មួយចំនួនយកពីឈើខ្មៅ កោះទាវ អូរឃ្លួនអីក៏យកមកជាប់នៅ មន្ទីរសន្តិសុខក្បាលដំរីក្រោមនេះដែរ ។ ក្បាលដំរីក្រោមជាមន្ទីរសន្តិសុខ របស់ស្រុក១៨ ។ នៅឆ្នាំ ១៩៧៥មន្ទីរសន្តិសុខក្បាលដំរីត្រូវបានដូរយកទៅធ្វើជាមន្ទីរសន្តិសុខនៅភូមិជ្រុង រមាស ខាងត្បូងវត្តជ្រុងរមាសវិញ ដែលមានចម្ងាយប្រហែល៣គីឡូម៉ែត្រពីទីតាំងក្បាលដំរីក្រោម ។ លោក តាពុំបានដឹងចំនួនអ្នកស្លាប់ និងចំនួនរណ្តៅពិតប្រាកដទេ ពីព្រោះនៅឆ្នាំ១៩៧៥គាត់ត្រូវបានជម្លៀសទៅនៅ

ព្រែកជ្រៃជិតទល់ដែន រហូតដល់រំដោះប្រទេសជាតិឆ្នាំ ១៩៧៩គាត់ក៏បានត្រឡប់មកស្រុកកំនើតវិញ ហើយបានចូលទៅឃើញទីតាំងសម្លាប់លែបិតនៅក្រោយផ្ទះរបស់គាត់ ប្រហែល២រយម៉ែត្រ គឺមានអន្លង់នៅតាពីសតាពាសពេញទឹកពេញដី តាមការប៉ាន់ស្មានរបស់គាត់ចំនួនជនរងគ្រោះសរុបប្រហែលជារាប់ពាន់នាក់ ។ លោកតា ហែម ឆឹង បានប្រាប់ទៀតថា នៅទីតាំងក្បាលដំរីនេះ មិនមែនត្រឹមតែយកប្រជាជនមកសម្លាប់តែប៉ុណ្ណោះទេ លោកសង្ឃក៏មានមកស្លាប់នៅទីនេះដែរ ។ លោកតា ហោ គី អាយុ៨០ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្បាលដំរីក្រោម ឃុំកំពង់កង់ ស្រុកកោះធំ សម័យខ្មែរក្រហមក៏បានរស់នៅក្នុងភូមិ ឃុំ ស្រុកដដែល ។ លោកតា ហោ គី មានប្រសាសន៍ ទីតាំងមន្ទីរសន្តិសុខក្បាលដំរីក្រោមស្ថិតនៅខាងជើងអ្នកតាថ្មសម័យខ្មែរក្រហមគឺគេយកផ្ទះរបស់លោកតា ហែម ឆឹង ធ្វើជាមន្ទីរសន្តិសុខ ហើយកន្លែងសម្លាប់គឺនៅក្រោយផ្ទះលោកតាឆឹងតែម្តង ។ គាត់ប្រាប់ថានៅក្នុងឆ្នាំ១៩៧៣ នៅក្នុងឃុំកំពង់កង់ចាប់ផ្តើមហូបបាយរួម ហើយអ្នកមកជាប់នៅទីនេះគឺគ្រាន់តែខុសបន្តិចបន្តួចក៏យកទៅសម្លាប់ដែរ ការសម្លាប់នៅទីនេះគឺសម្លាប់ពេលយប់ គាត់បានឮក្មួយគាត់និយាយថា ឃើញស្លឹកគ្រប ដល់ពេលបើកមើលឃើញខ្មោចកប់នៅហ្នឹងពីរនាក់បីនាក់ រួចគ្រាន់តែលប់ដីពង្រាបៗពីលើតែប៉ុណ្ណោះ ។ លោក ហោ គី ក៏បានប្រាប់ដូចលោកអ៊ំ ហែម ឆែម ដែរ ថានៅទីក្បាលដំរីនេះបង្កើតនៅឆ្នាំ១៩៣ដល់១៩៧៤តែប៉ុណ្ណោះ លុះដល់ឆ្នាំ១៩៧៤-១៩៧៥ មន្ទីរនេះត្រូវផ្លាស់ទៅធ្វើនៅជ្រុងរមាស រួចក៏ផ្លាស់ទៅព្រៃឬស្សី ហើយចុងក្រោយគឺយកទៅពោធិទន្លេ។ ពោធិទន្លេជាមន្ទីរសន្តិសុខដ៏ធំហើយសម្លាប់ច្រើនជាងគេនៅក្នុងស្រុកកោះធំណោះ ។ លោក ជ្រិន សា អាយុ៥២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្បាលដំរីក្រោម ឃុំកំពង់កង់ ស្រុកកោះធំ សម័យប៉ុល ពតក៏រស់នៅភូមិ ឃុំ ស្រុកដដែល ។ លោកពូក៏បានដឹងថា នៅឃុំកំពង់កង់ពួកខ្មែរក្រហមពិតជាបានយកផ្ទះលោកតាឆឹងធ្វើជាមន្ទីរសន្តិសុពិតប្រាកដមែន ។ ជនរងគ្រោះដែលយកមកដាក់នៅមន្ទីរសន្តិសុខនេះ ភាគច្រើនគឺជាអ្នកដែលពាក់ព័ន្ធរឿងសីលធម៌ ដូចជាយុវជនយុវនារីស្រឡាញ់គ្នាក៏យកមកកាក់ដែរ និង ម្ចាភិបាលខ្មែរក្រហមដែលខុសសីលធម៌ក៏មានយកមោដាក់នៅហ្នឹងដែរ ដល់នៅមន្ទីរនេះបានមួយរយៈទើបគេយកបញ្ជូនទៅមន្ទីរអប់រំតំបន់ ១៥ ។ មន្ទីរតំបន់១៥នៅកន្លែងអង់កូ ខាងជើងនម្ទីរក្បាលដំរីនេះ អ្នកដែលមានទោសកំហុសធ្ងន់គឺគេបេះតែបញ្ជូនឡើងទៅលើបន្តទៀត ។ អ្នកទោសដែលជាប់នៅនម្ទីរសន្តិសុខក្បាលដំរីក្រោមនេះមានរួចខ្លះ ដូចជាអ្នកដែលមានទោសស្រាល គឺមានរួចមកវិញខ្លះ ។ លោកពូក៏បានដឹងទីតាំងសម្លាប់ចុំសាក្សីមុនៗដែរ ផ្ទះលោកតាឆឹងគឺជាមន្ទីរសន្តិសុខ ហើយទីតាំងសម្លាប់គឺនៅចំពីក្រោយផ្ទលោកតាឆឹងតែម្តង លោក ជ្រិន សា បានប្រាប់ពីទីកន្លែងសម្លាប់ថា ឥឡូវទីតាំងនេះត្រូវបានប្រជាជនកាប់គាស់ធ្វើស្រែអស់ហើយ ហើយរណ្តៅដែលពួកខ្មែរក្រហមកប់នៅក្រោមដើមស្វាយដើមអីនោះត្រូវបានរលប់រាបស្មើអស់ដែរ ។ គាត់បានធ្វើការប៉ាន់ស្មានចំនួនរណ្តៅនៅទីតាំងនេះគឺមានចំនួនរាប់រយរណ្តៅ ក្នុងរណ្តៅនីមួយគឺមានសាកសពចាប់ពី៣នាក់ទៅ៨នាក់

លោកពូបានប្រាប់ថាមន្ទីរសន្តិសុខក្បាលដំរីក្រោមនេះគឺមានឈ្មោះ យុន ជាអ្នកគ្រប់គង គាត់ប្រាប់ថាយុនមានអាយុប្រហែលនឹងគាត់ដែរ ។ យុនត្រូវបានស្លាប់បន្ទាប់ពីពួកនិរតីមកពីខាងតាកែវចូលមកស្រុកកោះធំនេះ ហើយបានស្រាវជ្រាវរកកម្មាភិបាលខ្មែរក្រហមនៅស្រុកកោះធំទាំងអស់យកទៅដាក់នៅគុក សន្តិសុខជ្រៃអូញ្ញោ ខេត្តកំពង់ស្ពឺ ។ លោកពូបានប្រាប់អំពីមូលហេតុផ្ទះតាឆឹងធ្វើជាមន្ទីរសន្តិសុខ ពីព្រោះនៅទីនោះមានផ្ទះពីរបីនៅជាប់គ្នា ផ្ទះនៅចន្លោះខាងត្បូងក៏ធំ ហើយម្ចាស់ផ្ទះដែលនៅជាប់ផ្ទះតាឆឹងនោះ គឺមានជម្ងឺស្លាប់ទាំងអស់ទុកផ្ទះនៅទំនេរ ដូច្នេះពួកខ្មែរក្រហមក៏បានយកទាំងផ្ទះតាឆឹងធ្វើជាមន្ទីរសន្តិសុខ ដោយយល់ឃើញថាផ្ទះទាំងបីនេះសុទ្ធតែធំៗងាយស្រួលដាក់អ្នកទោស ។ លោកពូមិនដែលបានដឹងអំពីរបៀបសួរចម្លើយអ្នកទោសពីសំណាក់ពួកខ្មែរក្រហមទេ ពីព្រោះមន្ទីរសន្តិសុខក្បាលរីក្រោមនេះ ធ្វើរងសុទ្ធតែបន្លាឬស្សីរះជុំវិញ ហើយគ្មានប្រជាជនណាហ៊ានចូលជិតបានទេ ។ នៅក្រោយរំដោះឆ្នាំ១៩៧៩ទើបលោកពូបានចូលមោមានឃើញនៅសេសសល់ខ្នោះដែកសំរាប់ដាកកដើងហើយនឹងមានរនុកដែកស៊កពីជញ្ជាំងម្ខាងទៅជញ្ជាំងម្ខាងទៀត ។

## ៧) ស្រុកល្វាឯម

ស្រុកល្វាឯមជាស្រុកដែលស្ថិតនៅអមតាមដងទន្លេមេគង្គ ទិសខាងកើតទីក្រុងភ្នំពេញស្ថិតនៅក្នុងភូមិភាគបូព៌ា ក្រុមមជ្ឈមណ្ឌលឯកសារកម្ពុជាមួយក្រុមបានធ្វើដំណើរឆ្ពោះទៅកាន់ទីតាំងទួលលាបដែលស្ថិតនៅក្នុងភូមិផ្លូវត្រី ឃុំថ្មគរតែម្តង ដោយពុំបានចូលជួបអភិបាលស្រុកឡើយ ដោយសារទីតាំងសាលាស្រុកនិងទីតាំងសម្រាប់ទួលលាបនៅឆ្ងាយពីគ្នា ម្យ៉ាងខែនេះជាខែទឹកតំឡើងផង មធ្យោបាយធ្វើដំណើរតាមផ្លូវទឹករហូត ។

**ទីតាំងទួលលាប** **លេខកកូដ ០៨០៦០៨**

**រយៈកំពស់(N) ១១ំ ៣០' ៥៩: ២៧** **រយៈទទឹង(E) ១០៥ំ ០៧' ១១: ៩១**

ទួលលាបគឺជាទីតាំសម្ងាប់នៅក្នុងរបកម្ពុជាប្រជាធិបតេយ្យ ស្ថិតនៅក្នុងភូមិផ្លូវត្រី ឃុំថ្មគរ ស្រុក ល្វាឯម ខេត្តកណ្តាល ទិសដៅចេញពីភ្នំពេញ តាមផ្លូវជាតិលេខ១ប្រហែល២៨គីឡូម៉ែត្រដល់រោងចក្រក្តារ បន្ទុះរូបជិះទូកឆ្លងកាត់ទន្លេមេគង្គដល់កំពង់ទូកភូមិផ្លូវត្រី ចេញពីកំពង់ទូកប្រហែល៦០០ម៉ែត្រដល់ផ្ទះប្រធានឃុំ ទីតាំងសម្ងាប់នៅក្រោយផ្ទះប្រធានឃុំចម្ងាយ៧០០ម៉ែត្រ ។ លោក វ៉ាន់ អាន អាយុ៥៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិថ្មគរ ឃុំផ្លូវត្រី ស្រុកល្វាឯមខេត្តកណ្តាល តួនាទីជាជំទប់លេខ៣ ។ លោកពូជាប្រជាជនចាស់ធ្លាប់រស់នៅភូមិ ឃុំ ស្រុកដដែលតាំងពីមុនរហូតមកដល់សព្វថ្ងៃ ។ ឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩លោកពូជាកសិកររស់នៅក្នុងភូមិផ្លូវត្រីមួយរូប ដែលខិតខំធ្វើការងារបំរើឲ្យពួកខ្មែរក្រហមទាំងឈឺទាំងជាដើម្បីប្តូរយកបរបមួយចានដើម្បីចិញ្ចឹមជីវិត ។ គាត់បន្តទៀតថា ពេលធ្វើការចប់ម៉ោង១១ គឺត្រូវប្រជុំបំពាក់សតិអារម្មណ៍ឲ្យយល់ដឹងពីការងាររបស់អង្គការថ្នាក់លើ (របបកម្ពុជាប្រជាធិបតេយ្យ) ។ មុនហូបបាយត្រូវប្រជុំជីវភាព

យៈពេលកន្លះម៉ោងទើបហូបបាយ ទាំងព្រឹកទាំងល្ងាច ដោយមានការបើកអង្គប្រជុំពីប្រធាន«គ»យុវជនវ័យកណ្ដាល មានពេលខ្លះក៏មានការប្រជុំនៅតាមសហករណ៍ ដោយមានគណៈស្រុកឈ្មោះថុងជាអ្នកបើកអង្គប្រជុំ ។ ពេលប្រជុំម្ដងៗប្រធានសហករណ៍តែងតែរំលឹកស្មារតីដល់បងប្អូនប្រជាកសិករឲ្យប្រឹងខិតខំធ្វើការងារដើម្បីដោះស្រាយជីវភាពសហករណ៍ឲ្យបានសំបូរហូប អ្នកណាដែលដំពើបដំពើមនឹងការងារ «ទុកក៏មិនចំណេញដក ចេញក៏មិនខាត» ទ្រឹស្ដីមួយទៀតដែលប្រធានសហករណ៍តែងតែលើកឡើងនោះគឺ«មហាលោតផ្លោះមហាអស្ចារ្យ» ។ គ្រប់កម្មាភិបាលខ្មែរក្រហមទាំងអស់តែងតែងប្រើពាក្យនឹងទាំងអស់ នៅពេលប្រជុំម្ដងៗ ។ អ្នកដែលឈឺច្រើន ជួនកាលឲ្យហូបបបរ ជួនកាលមិនឲ្យហូបទៀត ដោយយល់ថាអ្នកដែលឈឺពុំបានបញ្ចេញ ពលកម្មដើម្បីផលប្រយោជន៍ដល់ពួកគេ ។ អ្នកឈឺមួយចំនួនធំត្រូវស្លាប់ដោយសាការអត់អាហារហើយមួយចំនួនទៀតស្លាប់ដោយ សារការធ្វើទារុណកម្មរួចយកទៅសម្លាប់ក៏មាន ។ ជនរងគ្រោះដែលស្លាបនៅទួលលាបមុននឹងសម្លាប់គឺពួកខ្មែរក្រហមយកមកដាក់នៅមន្ទីរសន្តិសុខសិនទើបយកទៅសម្លាប់ អ្នកទោសទាំងនោះគឺយកមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ បើតាមដែលលោកអ៊ឹមានប្រសាសន៍ថា ពេលបែកឆ្នាំ១៩៧៥ភ្លាមអ្នកដែលជម្លៀសមកពីទីក្រុងភ្នំពេញ តែងតែយកខោអាវយកមកដូរស្បៀង ដូចជាម្ហូបម្ហាសំរាប់ហូបចុកនឹងក៏ចាប់យកដាក់នៅមន្ទីរសន្តិសុខទួលលាបនេះដែរ ។ លោកពូ វ៉ាន់ អានពុំបានឃើញពួកខ្មែរក្រហមសម្លាប់ជនរងគ្រោះដោយផ្ទាល់ភ្នែកក៏ពិតមែន ប៉ុន្តែគាត់ហ៊ានអះអាងថានៅសម័យខ្មែរក្រហមពិតជាមានការកាប់សម្លាប់ប្រជាជននៅក្នុងភូមិផ្លូវត្រី ឃុំថ្មគរក៏ដូចជាប្រជាជនទៅទូទាំងឃុំក្នុងស្រុកល្វាឯមពិតប្រាកដមែន ពីព្រោះនៅក្រោយឆ្នាំរំដោះប្រទេសជាតិថ្ងៃ៧មករា ឆ្នាំ១៩៧៩លោកពូបានចូលទៅទីតាំងទួលលាបបានឃើញរណ្ដៅសាកសពចំនួន១៣រណ្ដៅនិងឡូសំរាប់ដាក់សាកសពជនរងគ្រោះចំនួនមួយទៀតផង ។ គាត់ប្រាប់បន្តទៀតថារណ្ដៅនីមួយៗមានទំហំ៣ម៉ែត្រ៤ជ្រុង គាត់បានប៉ាន់ស្មាន ជនរងគ្រោះដែលស្លាប់នៅទួលលាបក្នុងមួយរណ្ដៅមានចំនួនពី២០នាក់ឡើងទៅ ហើយនៅក្នុងឡូមួយមានចំនួនប្រហែលជា៥០នាក់ ដូច្នេះការសន្និដ្ឋានចំនួនជនរងគ្រោះសរុបនៅក្នុងទីតាំងទួលលាបនេះពី៣០០ទៅ៣៦០នាក់ ។ លោកពូ វ៉ាន់ អាន បានប្រាប់ថាមន្ទីរសន្តិសុខនៅក្នុងឃុំថ្មគរទាំងមូលគឺមានរយៈពេលតែមួយឆ្នាំតែប៉ុណ្ណោះ(១៩៧៥ - ១៩៧៦) ចាប់ពីឆ្នាំ១៩៧៦ ប្រជាជនដែលមានទោសកំហុសផ្សេងៗគឺចាប់យកទៅដាក់នៅមន្ទីរសន្តិសុខវត្តបារ៉ុងខ្នុររកា និងមន្ទីរសន្តិសុខ វត្តស្វាយវិញ ។ លោកពូបានបញ្ជាក់ប្រាប់ដល់ក្រុមស្រាវជ្រាវយើងជាលើកចុងក្រោយអំពីការធ្វើទារុណកម្ម ចំពោះលោកសង្ឃមួយអង្គព្រះនាម គង់ វ៉ាន វិន័យធរវត្តថ្មគរ ពួខ្មែរក្រហមបានផ្សឹកព្រះអង្គរួចបង្ខំឲ្យព្រះអង្គក្រងព្រួល ដោយព្រះអង្គជាអ្នកបួសរៀនពុំចេះក្រងព្រួលដូច្នេះហើយបានជាពួកខ្មែរក្រហមវាយធ្វើបាបព្រះអង្គរហូតដល់សុគតតែម្ដង ។ មីង យូ អាន អាយុ៤១ឆ្នាំ ជាប្រជាជនរស់នៅភូមិផ្លូវត្រីឃុំថ្មគរ ស្រុកល្វាឯមរហូតតាំងពីមុនរហូតមកដល់បច្ចុប្បន្ននេះ ដូច្នេះគាត់(យូ អាន) បានដឹងអំពីសកម្មភាព

របស់ពួកខ្មែរក្រហម ដែលបានធ្វើមកលើប្រជាជនក្នុងភូមិរបស់គាត់កន្លងមកដោយដាក់ស្តែងតែម្តង ។ ឆ្នាំ ១៩៧៥ពួកខ្មែរក្រហមបានហៅបងថ្លៃរបស់គាត់ឲ្យទៅរៀនសូត្រ ហើយពួកវា(សន្តិសុខខ្មែរក្រហម) បានចាប់ប្រុសៗវ័យកណ្តាលដែលថា យកទៅរៀនសូត្រយកមកដាក់នៅផ្ទះបងថ្លៃរបស់គាត់នៅពេលយប់ ពេលថ្ងៃគឺឲ្យអ្នកទាំងអស់នោះទៅធ្វើការនៅកន្លែងទីតាំងទួលលាប ហើយយប់ត្រលប់មកដេកនៅផ្ទះបងថ្លៃរបស់វិញ ។ ក្រោយពីត្រលប់មកពីធ្វើការវិញអ្នកទាំងអស់នោះមិនដែលហ៊ាននិយាយអ្វីទាំងអស់ ទោះបីមីង យូ អាន លួចសួរអំពីការងារនៅទួលលាបយ៉ាងណាៗនោះក៏ពុំហ៊ាននិយាយដែរ ព្រោះនៅទីនោះមានប្រធានសន្តិសុខឈ្មោះតាឡឹងជាអ្នកដឹកនាំឲ្យទៅធ្វើការ ម្នាក់ៗហាក់បីដូចជាខ្លាចនៅអំណាចតាឡឹងយ៉ាងខ្លាំង គ្រាន់តែតាឡឹងគ្រហែមតែបន្តិចខ្លាចឡើងញ័រខ្លួន ។ មីង យូ អាន បានប្រាប់ថាតាឡឹងបានស្លាប់បាត់ទៅហើយ ប៉ុន្តែសព្វថ្ងៃសន្តិសុខម្នាក់នៅរស់គឺឈ្មោះណាល់ រត់ទៅនៅភូមិព្រៃកក្រូច តែឥឡូវបានទៅធ្វើការនៅភ្នំពេញបាត់ហើយ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៥លោកមីងបានឃើញពួកគេ(ខ្មែរក្រហម) បណ្តើរជនរងគ្រោះទាំងខ្សែៗពីមន្ទីសន្តិសុខភូមិផ្លូវត្រីសំដៅទៅសន្តិសុខវត្តសំពោងនិងទីតាំងសម្លាប់ទួលលាប ជនរងគ្រោះភាគច្រើនជាទាហាន គ្រូប៉ូលីសជាដើម ។ មីង យូ អានបានប្រាប់បន្តទៀតថា ឆ្នាំដែលកងទ័ពវៀតណាមកំពង់តែរំដោះប្រទេសជាតិគាត់បានឃើញប្រធានឃុំថ្មគរឈ្មោះឡេងដែលទើបផ្លាស់មកពីខេត្តតាកែវ លីចបកាប់នៅមុំស្ពានតាប៉ម នៅលើក្បាលចបគឺពោរពេញទៅដោយឈាមឡើងក្រមរ្លៅទៀតផង ដូច្នេះអ្នកមីងសន្និដ្ឋានថាជនរងគ្រោះដែលបណ្តើរទាំងខ្សែៗសំដៅទៅវត្តសំពោងនិងទីតាំងសម្លាប់ទួលលាបនេះ គឺពិតជាបណ្តើរយកទៅសម្លាប់ពិតប្រាកដមែន ។